រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ :០០៥ សសរ ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី២៣..ខែ.០៣..ឆ្នាំ ២០០៤

# សេចក្តីណែនាំ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់

. យោងមាត្រា ២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១

. យោងមាត្រា ១៩ នៃអនុក្រឹត្យ លេខ ២២ អនក្របក ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរ វិមជ្ឈការអំណាចតួនាទី និង ភារៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់មេឃុំ ចៅសង្កាត់ ដូចតទៅ :

១. គោលបំណង :

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មាធិការមួយឈ្មោះថា "គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ សង្កាត់" ដើម្បីជួយធ្វើការងាររបស់ខ្លួន ។

ការបង្កើតគណៈកម្មាធិការនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីអនុវត្តន៍តួនាទី និងភារកិច្ចទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចការនារី និងកុមារនៅឃុំ សង្កាត់ ។

២. សមាសភាព :

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ត្រូវមានសមាសភាពដូចតទៅ :

| | |
|---|---|
| . មេឃុំ ចៅសង្កាត់ | ជាប្រធាន |
| . ជំទប់ទី២ ចៅសង្កាត់រងទី២ | ជាអនុប្រធាន |
| . អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | ជាសមាជិកអចិន្ត្រៃយ៍ |
| . តំណាងមណ្ឌលសុខភាព ១ រូប | ជាសមាជិក |
| . តំណាងគ្រូបង្រៀន ១ រូប | ជាសមាជិក |

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ត្រូវមានសមាជិកពី ៥ ទៅ ៧រូប ដោយ យោងទៅតាមទំហំការងារ និង ស្ថានភាពជាក់ស្តែងនៅក្នុងឃុំ សង្កាត់ នីមួយៗ ។ គណៈកម្មាធិការនេះ ត្រូវមាន សមាជិកជានារីយ៉ាងតិច ៤០ ភាគរយ ។

៣. តួនាទី និងភារកិច្ច របស់គណៈកម្មាធិការ :

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ :

- ផ្សព្វផ្សាយជូនប្រជាពលរដ្ឋអោយយល់ជ្រួតជ្រាបអំពីសិទ្ធិនារីនិងកុមារនៅឃុំ សង្កាត់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការប្រមូលពត៌មានពាក់ព័ន្ធនឹងផលប្រយោជន៍នារីនិងកុមារដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគពាវរិកលរបស់ឃុំ សង្កាត់ ព្រមទាំងពិនិត្យ តាមដានការអនុវត្តន៍ផែនការសកម្មភាពដែលពាក់ព័ន្ធនារីនិងកុមារ
- ចូលរួមក្នុងការអនុវត្តផែនការសកម្មភាពឃុំ សង្កាត់ ទៅតាមតំរូវការ
- លើកកំពស់ការយល់ដឹងរបស់សមាគមន៍ និងបំផុសចលនាសង្គម ព្រមទាំងពិនិត្យតាមដានស្ថានភាពនារីនិងកុមារ បីដងក្នុងមួយឆ្នាំ លើផ្នែកសុខភាពនិងអាហារូបត្ថម្ភ ផ្នែកអប់រំ និងផ្នែកកិច្ចការពារ
- ពង្រឹងនូវការប្រាស្រ័យទាក់ទង កិច្ចសហការ និងការសំរបសំរួលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពក្នុងឃុំ សង្កាត់របស់ខ្លួន
- ស្វែងរកមតិគាំទ្រក្នុងគោលបំណងដើម្បីអោយនារីបានចូលរួមធ្វើសេចក្តីសំរេច
- ធ្វើរបាយការណ៍ទៀងទាត់ពាក់ព័ន្ធកិច្ចការនារីនិងកុមារជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ពាក់ព័ន្ធកិច្ចការនារីនិងកុមារ ជូនក្រុមប្រឹក្សាឃុំ សង្កាត់តាមការអញ្ជើញ ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចអញ្ជើញប្រធានជាតំណាងគណៈកម្មាធិការ ឬសមាជិកគណៈកម្មាធិការទាំងមូល ។

ដើម្បីបំពេញតួនាទីនិងភារកិច្ចដូចមានក្នុងចំណុចបិខាងលើ គណៈកម្មាធិការនេះត្រូវសំរបសំរួល និងសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាអ្នកផ្តល់សេវាកម្មពាក់ព័ន្ធផ្នែកសង្គម និងអ្នកស្ម័គ្រចិត្តភូមិនានានៅឃុំ សង្កាត់ និងសហគមន៍ ។

៤. តួនាទី និងភារកិច្ច សមាជិកនីមួយៗ :

ក. ប្រធាន :

- គណៈកម្មាធិការដឹកនាំដោយមេឃុំ ចៅសង្កាត់ ។ ពេលប្រធានគណៈកម្មាធិការអវត្តមាន ត្រូវផ្ទេរសិទ្ធិទៅអនុប្រធាន ។
- អញ្ជើញសមាជិកគណៈកម្មាធិការ និងជាអធិបតីនៃអង្គប្រជុំទៀងទាត់របស់គណៈកម្មាធិការ
- អញ្ជើញសមាជិកគណៈកម្មាធិការ និងតំណាង២រូបមកពីគ្រប់ភូមិ ដែលជាសមាជិករបស់គណៈកម្មាធិការកសាងផែនការនិងថវិកា និងជាអធិបតីនៃការប្រជុំចមាស
- ធានាឱ្យមានរបាយការណ៍ទៀងទាត់ស្តីពីការងាររបស់គណៈកម្មាធិការជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។ /

ខ. អនុប្រធាន ៖

. ទទួលភារកិច្ចជំនួសប្រធាន ពេលប្រធានអវត្តមាន

. បំពេញភារកិច្ចបន្ថែមតាមការស្នើសុំរបស់ប្រធាន

.ករណីអនុប្រធានអវត្តមានអាចផ្ទេរភារកិច្ចទៅសមាជិកអចិន្ត្រៃយ៍ដឹកនាំការងារជំនួស ។

គ. សមាជិកអចិន្ត្រៃយ៍ ៖

. រៀបចំសេចក្តីព្រាងផែនការការងារប្រចាំឆ្នាំ និងពិនិត្យការអនុវត្តន៍ការងារកន្លងមក

. រៀបចំចាត់ចែងអង្គប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ និងការប្រជុំរួមាលជាមួយតំណាងភូមិ ដែលជាសមាជិករបស់គណៈកម្មាធិការ កសាងផែនការនិងថវិកា

. សំរបសំរួល និងទំនាក់ទំនងជាមួយតំណាងភូមិ ដែលជាសមាជិករបស់គណៈកម្មាធិការ កសាងផែនការនិងថវិកា ព្រមទាំងអ្នកទាក់ទិនក្នុងសកម្មភាពនានា ពាក់ព័ន្ធកិច្ចការនារីនិងកុមារនៅឃុំ សង្កាត់

. សំរបសំរួលដំណើរការចាត់ស្មានស្ថានភាពនារីនិងកុមារ ព្រមទាំងបញ្ហា និងវិភាគដែលមានដែលជាលទ្ធផលនៃការចាត់ស្មាន

. សំរបសំរួល និងស្នើបញ្ចូលនូវតំរូវការទាំងឡាយពាក់ព័ន្ធនារីនិងកុមារនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់

តួនាទីនិងភារកិច្ច ដូចបានកំណត់ក្នុងចំណុច "៤ខ" ខាងលើ នឹងជួយក្នុងការបំពេញតួនាទី និងភារកិច្ចរបស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ។

ឃ. សមាជិកគណៈកម្មាធិការ ៖

. ចូលរួមពិនិត្យពិភាក្សាសេចក្តីព្រាងផែនការការងារប្រចាំឆ្នាំ និងពិនិត្យការអនុវត្តន៍ការងារកន្លងមក

. ធានាការអនុវត្តន៍សកម្មភាពដែលបានគ្រោងទុកនៅឃុំ សង្កាត់

. ពិនិត្យតាមដានភាពរីកចំរើន បញ្ហាប្រឈមនៅឃុំ សង្កាត់ និងលើកអនុសាសន៍ ដើម្បីដោះស្រាយ។

៥. ការប្រជុំ ៖

គណៈកម្មាធិការនេះ មានរបបប្រជុំការងារជាទៀងទាត់ប្រចាំខែ និង មានការប្រជុំរួមាល ពីរដងក្នុងមួយឆ្នាំ ដើម្បី ៖

. អនុម័តផែនការប្រចាំឆ្នាំ និងពិនិត្យឡើងវិញនូវការអនុវត្តន៍សកម្មភាពរបស់គណៈកម្មាធិការ

. ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពនៅឃុំ សង្កាត់

. ពិភាក្សាពិភាពរីកចំរើន បញ្ហាប្រឈម និងលើកអនុសាសន៍ ដើម្បីដោះស្រាយ ⁄

. ពិភាក្សាអំពីជំហានបន្ទាប់ក្នុងការអនុវត្តផែនការសកម្មភាពនៅឃុំ សង្កាត់ ។

**គណៈកម្មាធិការត្រូវប្រជុំពីរដងក្នុងមួយឆ្នាំជាមួយតំណាងភូមិ ដើម្បី :**

. រៀបចំការដាក់បញ្ចូលតម្រូវការនារីនិងកុមារទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ។ កិច្ចប្រជុំនេះធ្វើឡើងក្រោយការចាត់ស្នាន់ស្ថានភាពនារីនិងកុមារលើកទី២

. រៀបចំការអនុវត្តន៍ដើម្បីដោះស្រាយតម្រូវការនារីនិងកុមារ នៅក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំឃុំ សង្កាត់បញ្ចប់ ។

## ៦. តំណាងភូមិ :

តំណាងភូមិដែលជាសមាជិកគណៈកម្មាធិការផែនការ និងថវិកា មានតួនាទី និង ភារកិច្ច :

. រៀបចំ និងសំរបសំរួលសកម្មភាពនានារបស់គណៈកម្មាធិការនិងចូលរួមក្នុងការអនុវត្តន៍ការងារក្នុងភូមិ

. បំផុសអ្នកភូមិអោយចូលរួមក្នុងសកម្មភាពរបស់គណៈកម្មាធិការ

. ពិនិត្យតាមដានការងារអនុវត្តន៍សកម្មភាពនានាដែលមានក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ពាក់ព័ន្ធនារីនិងកុមារ

. ពិនិត្យតាមដានស្ថានភាពនារីនិងកុមារជាទៀងទាត់នៅក្នុងភូមិ ។

## ៧. អន្តរកាល :

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំបង្កើតគណៈកម្មាធិការដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ សំរាប់អនុវត្តនៅក្នុងខេត្ត ក្រុងគោលដៅដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ ។

មេឃុំ ចៅសង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រី